# មន្ត្រីសិទ្ធិមនុស្ស៖ ការព្រមានរបស់សមត្ថកិច្ចប្ដឹងសកម្មជនលោក នី ណាក់ ជាទម្រង់នៃការរឹតត្បិតសិទ្ធិជាមូលដ្ឋាន។




លោក នី ណាក់ ផ្ដល់បទសម្ភាសន៍ដល់អ្នកសារព័ត៌មានវីអូអេ នៅក្បែររូបសំណាកយាយពេញ ក្បែរវត្តភ្នំ ក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣។ (លាស់ លីបលីប/វីអូអេ)
ចែករំលែក

ក្រុមអង្គការសង្គមស៊ីវិល ដែលធ្វើការលើផ្នែកសិទ្ធិមនុស្ស ចាត់ទុកថា ការព្រមានរបស់សមត្ថកិច្ចប្ដឹងលោក នី ណាក់ ពាក់ព័ន្ធជាមួយការថ្លែងរបស់សកម្មជនសង្គមរូបនោះដែលថា សមត្ថ

កិច្ចបានយកគ្រឿងញៀនក្លែងក្លាយមកដុតបំផ្លាញចោលនោះគឺជាទម្រង់នៃការរឹតត្បិតសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ដែលជាធាតុសំខាន់មួយនៃការអនុវត្តរបបប្រជាធិបតេយ្យ។

កាលពីចុងឆ្នាំ២០២២ លោក នី ណាក់ បានសរសេរសារមួយបង្ហោះនៅលើគេហទំព័ររបស់លោកថា សមត្ថកិច្ចបានយកសារធាតុផ្សេងៗមកដុតបន្លំថាជាសារធាតុញៀន។ ក្រោយការបង្ហោះរបស់លោក មន្ត្រីជាន់ខ្ពស់មួយរូបនៅអគ្គស្នងការដ្ឋាននគរបាលជាតិបានប្រាប់លោក នី ណាក់ ឲ្យចេញមកសុំទោសជាសាធារណៈដើម្បីបញ្ចៀសការយល់ច្រឡំពីមហាជន។ ប៉ុន្តែលោក នី ណាក់ បានបដិសេធចំពោះការស្នើសុំនោះ។

នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អ្នកស្រី ចក់ សុភាព កត់សម្គាល់ថា បុគ្គលសាធារណៈក៏ដូចជាស្ថាប័នរដ្ឋជាកម្មវត្ថុនៃការរិះគន់ពីសាធារណជន។ ដូច្នេះអ្នកស្រីថា ការប្ដឹងផ្ដល់ ឬក៏ចំណាត់ការផ្សេងៗមិនត្រូវបានលើកទឹកចិត្តឡើយ ដោយសារតែវាជាការបញ្ចេញមតិ។

នាយិការូបនេះប្រាប់វីអូអេនៅថ្ងៃព្រហស្បតិ៍នេះថា៖ «ស្ថាប័នរដ្ឋ ឬក៏អាជ្ញាធរពាក់ព័ន្ធហ្នឹង ក្នុងនាមជាបុគ្គលសាធារណៈ គួរតែមានការអត់ឱនខ្ពស់ ហើយជំនួសឲ្យការណ៍ដែលធ្វើការចោទប្រកាន់ ឬក៏ប្រើប្រាស់ធនធានរដ្ឋដើម្បីប្ដឹងតបមកពលរដ្ឋហ្នឹង ស្ថាប័នទាំងអស់ហ្នឹងគួរតែចេញផ្សាយនូវព័ត៌មានឆ្លើយតបនឹងការរិះគន់»។

អ្នកស្រី ចក់ សុភាព លើកឡើងទៀតថា ការប្ដឹងផ្ដល់មកលើប្រជាពលរដ្ឋមិនផ្ដល់ផលចំណេញអ្វីនោះឡើយ  ប៉ុន្តែវាជាការបង្ហាញថា អាជ្ញាធររឹតត្បិតលើសិទ្ធិសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋ។ អ្នកស្រីបន្ថែមថា លោកនី ណាក់ជាមុខសញ្ញានៃការតាមដាន ក្រោមហេតុផលថាលោកធ្លាប់ជាប់ពន្ធនាគារ។ ដូច្នេះអ្នកស្រីថា អាជ្ញាធរមិនគួរដៅមុខសញ្ញាចំពោះពលរដ្ឋណាម្នាក់ ពីព្រោះតែនិន្នាការនយោបាយ និងភាពសកម្មនៅក្នុងសង្គមឡើយ។

ទោះជាយ៉ាងណាក្ដី នាយិការូបនេះអះអាងថា សិទ្ធិសេរីភាពបញ្ចេញមតិមិនមែនជាសិទ្ធិផ្ដាច់មុខរបស់បុគ្គលណាម្នាក់នោះឡើយ ដែលវាតម្រូវឲ្យអ្នកបញ្ចេញមតិត្រូវតែស្វែងយល់ពីការទទួលខុសត្រូវរបស់ខ្លួនផងដែរ។

នាយកគ្រប់គ្រងកិច្ចការទូទៅនៃអង្គការសិទ្ធិមនុស្សលីកាដូ លោក អំ សំអាត យល់ថា ក្រោយចាកចេញពីពន្ធនាគារ លោកនី ណាក់បានធ្វើសកម្មច្រើននៅក្នុងកិច្ចការងារសង្គម ពាក់ព័ន្ធជាមួយនឹងការតស៊ូមតិ។ លោកបន្ថែមថា ភាពសកម្មក្នុងកិច្ចការសង្គមរបស់សកម្មជនរូបនេះទំនងជាមានជាប់ពាក់ព័ន្ធនឹងការត្រៀមចាត់វិធានការផ្លូវច្បាប់ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច។

បើតាមលោក អំ សំអាត អាជ្ញាធរគួរតែធ្វើការពិចារណាឲ្យបានច្បាស់លាស់មុនចាត់វិធានការ និងបែងចែកឲ្យច្បាស់រវាងសេរីភាពនៃការបញ្ចេញមតិ និងបទល្មើស និងថា  បើសិនជាអាជ្ញាធររឹតត្បិតទៅលើសេរីភាពនៃការបញ្ចេញមតិរបស់ពលរដ្ឋនោះ  នោះដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជានឹងរងផលប៉ះពាល់។

អ្នកការពារសិទ្ធិមនុស្សរូបនេះអះអាងថា ការរិះគន់របស់ប្រជាពលរដ្ឋដើម្បីស្ថាបនាជាកញ្ចក់ឆ្លុះបញ្ចាំងភាពឆកល្វែងរបស់រដ្ឋាភិបាល។

លោកថ្លែងថា៖ «ការរិះគន់ដើម្បីធ្វើការកែលម្អ ធ្វើការស្ថាបនា រិះគន់នូវចំណុចខ្វះខាតដែលអាជ្ញាធរមិនទាន់មានការបំពេញ អាហ្នឹងជារឿងសំខាន់ណាស់នៅក្នុងលទ្ធិប្រជាធិបតេយ្យ ដើម្បីឲ្យអាជ្ញាធរឬក៏រដ្ឋាភិបាលលោកពិនិត្យមើលថា តើគោលនយោបាយរបស់រដ្ឋាភិបាលអ្វីដែលមិនទាន់បានសម្រេចមួយរយភាគរយ និងមានការខ្វះចន្លោះ»។

វីអូអេមិនទាន់អាចសុំការអត្ថាធិប្បាយពីលោកនី ណាក់បាននៅឡើយទេ គិតត្រឹមរសៀលថ្ងៃព្រហស្បតិ៍នេះ។

យ៉ាងណាក៏ដោយ សកម្មជនរូបនោះត្រូវគេដឹងថា កំពុងដង្ហែក្បួនធម្មយាត្រាជាមួយមេដឹកនាំសហជីពលោករ៉ុង ឈុន និងសកម្មជនឯទៀតពីភ្នំពេញទៅបូជនីយដ្ឋានប្រវត្តិសាស្ត្រលោកឧកញ៉ាឃ្លាំង មឿងនៅខេត្តពោធិ៍សាត់ដើម្បីលើកកម្ពស់សីលធម៌សង្គម។

អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ លោក ឆាយ គឹមខឿន ប្រាប់វីអូអេតាមប្រព័ន្ធទំនាក់ទំនងតេឡេក្រាមនៅថ្ងៃព្រហស្បតិ៍នេះថា ការបញ្ចេញមតិរបស់លោកនី ណាក់ជាសិទ្ធិ

សេរីភាពរបស់គាត់ តែថា គាត់ត្រូវមានការប្រុងប្រយ័ត្នលើការប្រើប្រាស់ពាក្យសម្ដីដែលអាចបង្កជាបទល្មើសដែលមានចែងក្នុងច្បាប់។

លោកបញ្ជាក់ថា៖ «យើងខ្ញុំកំពុងតែពិចារណាហើយ ក៏ប៉ុន្តែមិនមែនចាត់ទុកគាត់ថា ជាដៃគូប្រកួតអីទេ។ ប៉ុន្តែយើងកំពុងតែពិចារណាទៅលើបញ្ហាផ្លូវច្បាប់ និងឥទ្ធិពលនៃសកម្មភាព ឬការផ្សព្វផ្សាយរបស់គាត់ ការបញ្ចេញមតិរបស់គាត់។ តើវាអាចជះឥទ្ធិពលដល់បរិយាកាសទូទៅរបស់សង្គម ដល់បរិយាកាសសន្តិសុខ ឬក៏ប៉ះពាល់ដល់ស្ថាប័នអនុវត្តច្បាប់ទៀតដែរអត់?»។

លោក នី ណាក់ អាយុ៤២ឆ្នាំ ម្ចាស់គណនីសង្គមហ្វេសប៊ុកឈ្មោះ IMan-KH ដែលមានជំនាញក្នុងវិស័យកសិកម្ម ត្រូវបានអ្នកការពារសិទ្ធិមនុស្សខ្លះអះអាងថា តែងតែរិះគន់ជាញឹកញាប់ដោយមិនសំចៃមាត់អំពីចំណុចខ្សោយរបស់រដ្ឋាភិបាលពាក់ព័ន្ធបញ្ហាអវិជ្ជមានដែលកើតឡើងក្នុងសង្គម។

លោកធ្លាប់ជាប់ពន្ធនាគារ១៨ខែ និងពិន័យជាប្រាក់ចំនួន២លានរៀលពីបទ«ជេរប្រមាថជាសាធារណៈ និងបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទ៍»ប្រព្រឹត្តនៅរាជធានីភ្នំពេញកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២០ តាមមាត្រា៣០៧ មាត្រា៤៩៤ និងមាត្រា៤៩៥នៃក្រមព្រហ្មទណ្ឌកម្ពុជា ក្រោយលោកសរសេរសារលើបណ្ដាញទំនាក់ទំនងសង្គមហ្វេសប៊ុក ដែលមានលក្ខណៈកំប្លែងរឿងទិញម៉ាស់ពាក់ឲ្យមាន់ អំឡុងពេលមានការឆ្លងរាតត្បាតជំងឺកូវីដ១៩៕